# សុន្ទរកថា
# របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
# ថ្លែងនៅក្នុងវេទិការជាតិ
# ស្តីពីគំនិតផ្តួចផ្តើមបឹងទន្លេសាប
# អ៊ីនធើកុងទីណង់តាល់ នាថ្ងៃទី ៥ ខែមិនា ឆ្នាំ២០០៧

*-ឯកឧត្តម គ្រីនវូត (Mr. Greenwood) អនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី*

*-ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ*

*-លោកស្រី និង អស់លោកទាំងអស់ជាទីមេត្រី*

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយជាអនេក ដោយបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវ លោកស្រី អស់លោកក្នុងវេទិកាជាតិស្តីពី***គំនិតផ្តួចផ្តើមបឹងទន្លេសាប (Tonle Sab Initiative)*** ដែលបានរៀបចំឡើងរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលគាំទ្រឱ្យមានវេទិកាជាតិនេះ ព្រមទាំងផ្តល់នូវការយកចិត្តទុកដាក់ទាំងខាងស្មារតី និងធនធានសម្រាប់ការអភិវឌ្ឍន៍ និងអភិរក្សបឹងទន្លេសាប ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា វេទិកាជាតិនេះនឹងក្លាយជាការដ្ឋានដ៏សំខាន់មួយសំរាប់កិច្ចពិភាក្សា ពិគ្រោះយោបល់ទៀងទាត់រវាងអ្នករៀបចំគោលនយោបាយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសហគមន៍មូលដ្ឋានដើម្បីជំរុញការអភិវឌ្ឍន៍ប្រកបដោយចិរភាព នៃអាងទន្លេសាបព្រមទាំងការការពារ និងអភិរក្សធនធានធម្មជាតិ ដែលជាប់ពាក់ព័ន្ធជាមួយវិសាលភាពនៃបឹងធម្មជាតិដ៏មានសារសំខាន់នេះ ។

ជាការពិត បឹងទន្លេសាបមិនត្រឹមតែជាប្រព័ន្ធអេកូឡូស៊ីមួយនៃព្រៃលិចទឹក ជម្រកត្រី និងកសិកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែបឹងនេះគឺជាផ្នែកមួយដ៏សំខាន់នៃមរតកវប្បធម៌ និងប្រវត្តិសាស្ត្រ ដែលកំណត់ពីអត្តសញ្ញាណជាតិ សម្រាប់ប្រទេសកម្ពុជាទៀតផង ។ ជាក់ស្តែង ទន្លេសាបបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ភាពសម្បូរបែបនៃសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងជោគវាសនារបស់ប្រសេកម្ពុជា អស់រយៈពេលជាច្រើនសតវត្សកន្លងមកហើយ ។ ដោយទទួលស្គាល់ពីសារប្រយោជន៍ ជាយុទ្ធសាស្ត្រនៃបឹងទន្លេសាបនេះ អតីតព្រះមហាក្សត្រខ្មែរទាំងអស់ដែលគ្រប់គ្រងអាណាចក្រខ្មែរចាប់ពីសតវត្សទី ៩ និង១៣ បានជ្រើសរើសយកតំបន់ជ្រោយមាត់បឹងទន្លេសាបសម្រាប់ជាមូលដ្ឋានដើម្បីកសាងរាជធានីនៃចក្រភពខ្មែរ ។ ទោះបីជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាបានប្តូរទៅក្រុងភ្នំពេញ ក្នុងពេលក្រោយមកក៏ដោយ ក៏បឹងទន្លេសាបនៅបន្តមានឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា រហូតមកដល់ពេលបច្ចុប្បន្ន ។

ដើម្បីចូលរួមចំណែកក្នុងកិច្ចពិភាក្សានេះ ខ្ញុំសូមចែករំលែកនូវគំនិតយោបល់មួយចំនួនជាមួយឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ស្តីពីបញ្ហាទន្លេសាប និងសូមលើកឡើងនូវចំនុចគន្លឹះដែលមានលក្ខណៈជាគោលនយោបាយខ្លះៗ ដើម្បីដោះស្រាយបញ្ហា ដែលទាក់ទងនឹងអាងទន្លេសាប ។

*-ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក*

ខ្ញុំសូមចាប់ផ្តើមដោយធ្វើការគូសបញ្ជាក់ថា បឹងទន្លេសាបគឺជាបឹងទឹកសាបធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍។ ប្រព័ន្ធអេកូឡូស៊ីបានបង្ហាញនូវបាតុភូតពិសេសតែមួយគត់ ដោយមានទន្លេសាបជាផ្លូវសម្រាប់ផ្គត់ផ្គង់ទឹកដល់ផ្ទៃបឹងទាំងមូលនិងជាដៃសម្រាប់បញ្ចេញបញ្ចូលទឹកពីទន្លេមេគង្គ ។ មានន័យថា នៅក្នុងរដូវវស្សាទន្លេសាបហូរនាំទឹកចូលទៅក្នុងបឹងធំ និងបញ្ចេញទឹកពីបឹងវិញនៅរដូវប្រាំង។ បាតុភូតដ៏អស្ចារ្យនេះ បានបង្កើតឡើងនូវតំបន់ដីសើមដ៏ធំល្វឹងល្វើយដែលផ្តល់ជម្រកដល់ជីវចម្រុះសម្បូរបែប ដូចជាមច្ឆាជាតិ បក្សាបក្សី សត្វល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ។ ជីវសាស្រ្តចម្រុះក្នុងតំបន់បឹងទន្លេសាប រួមមាន ពូជមច្ឆាជាតិ ២០០ ប្រភេទ សត្វល្មូន ៤២ ប្រភេទ បក្សាបក្សី ២២៥ ប្រភេទ និងថនិកសត្វ ៤៦ ប្រភេទ និងរុក្ខជាតិមានច្រើនជាង ២០០ ប្រភេទ។

ភាពសម្បូរបែបនៃជីវសាស្រ្តចម្រុះនេះ បានធ្វើអោយបឹងទន្លេសាបមានផលិតភាពយ៉ាងច្រើន សម្រាប់មុខរបរនេសាទ ក្នុងនោះបឹងទន្លេសាបជាកន្លែងនេសាទត្រីទឹកសាប ដែលមានផលិតភាពខ្ពស់ជាងគេបំផុតមួយនៅក្នុងពិភពលោក ហើយបានផ្តល់ជាធនធានធម្មជាតិប្រកបដោយប្រូតេអ៊ីន កាល់ស្យូម និងវិតាមីន ***អា*** ខ្ពស់ដល់ប្រជាជនកម្ពុជា។ ក្រៅពីផ្តល់នូវមុខរបរនេសាទ អាងទន្លេសាបគឺជាកន្លែងផ្គត់ផ្គង់ឈើ អុស និងផលិតផលកសិកម្មសំខាន់ៗផ្សេងទៀតជាច្រើន។ អាងទន្លេសាបជាប្រភពដ៏មានសក្តានុពលសម្រាប់ផ្តល់ទឹកប្រើប្រាស់ និងវារីអគ្គិសនី។ សព្វថ្ងៃនេះធនធានដី ទឹក និងជីវសាស្រ្តនៃបឹងទន្លេសាបបានផ្តល់ផលប្រយោជន៏ដល់ប្រជាជនប្រហែល ៤០% ក្នុងខេត្តទាំង ៦ ស្ថិតនៅជុំវិញបឹងទន្លេសាបព្រមទាំងផ្តល់សន្តិសុខស្បៀង និងការផ្គត់ផ្គង់ជីវភាពសម្រាប់ប្រជាជនកម្ពុជាទូទាំងប្រទេស។ ជាមួយគ្នានេះដែរ អាងទន្លេសាបបានផ្តល់ទីជំរកដល់ប្រជាជនប្រមាណ ៥លាន នាក់ដែលភាគច្រើនសុទ្ធតែជាអ្នកទាញផលប្រយោជន៏ដោយផ្ទាល់ ពីធនធានធម្មជាតិនៅទីនោះ។ ក្នុងនោះមានប្រជាជនប្រមាណជាងពាក់កណ្តាលរស់នៅពឹងផ្អែកលើបឹងទន្លេសាបនិងតំបន់ដីសើមជុំវិញបឹង។

ប្រជាកសិករមួយចំនួនដាំស្រូវឡើងទឹកនៅតាមទំនាបបឹងទន្លេសាប និងដាំស្រូវប្រដេញទឹកនៅរដូវទឹកស្រក។ ព្រមជាមួយនេះ បន្ទាប់ពីដំណាំស្រូវ ត្រីទឹកសាបនៃបឹងទន្លេសាបគឺជាផ្នែកមួយដ៏សំខាន់បំផុត សម្រាប់ការផ្គត់ផ្គង់ម្ហូបអាហាររបស់ប្រជាជនកម្ពុជា។

ដោយទទួលស្គាល់ពីសារសំខាន់ នៃអត្ថប្រយោជន៏ខាងផ្នែកសេដ្ឋកិច្ច និងបរិស្ថាន ចំពោះប្រទេសជាតិ និងប្រជាជនកម្ពុជា ដូចដែលខ្ញុំបានលើកឡើងខាងលើ បឹងទន្លេសាបត្រូវបានកំណត់ដោយព្រះរាជក្រិត្យនៅខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ថាជា ***តំបន់ការពារការប្រើប្រាស់ចម្រុះ (Multi-Use Protected Area)*** ។ លើសពីនេះទៀតនៅខែ តុលា ឆ្នាំ ១៩៩៧ បឹងទន្លេសាបត្រូវបានទទួលស្គាល់ថា ជាតំបន់ ***ជីវមណ្ឌលបម្រុង*** តាមរយៈកម្មវិធី ***មនុស្សនិងជីវមណ្ឌល*** របស់អង្គការយូនីស្កូ *(UNESCO)*។

ទន្ទឹមនឹងនេះ ទោះបីជាមានគំនិតផ្តួចផ្តើមទាំងនេះក៏ដោយ ក៏ការគ្រប់គ្រង ***ជីវមណ្ឌលបម្រុងបឹងទន្លេសាប*** នៅតែមានបញ្ហាប្រឈមសម្រាប់កម្ពុជា។ កិច្ចការនេះតម្រូវអោយមានការអនុវត្តន៏ជាជំហានៗ និងមានការគាំទ្រពីសហគមន៏ទាំងអស់ដែលរស់នៅតំបន់អាងទន្លេសាប និង ដែលពឹងអាស្រ័យកផងដែរ ទៅនឹងផលិតផល និងងសេវាកម្ម ដែលកើតមាននៅតំបន់ដ៏មានសារសំខាន់នេះ។ ជាមួយនេះដែរ ការគ្រប់គ្រងទឹកក្នុងទន្លេមេគង្គទាំងក្នុង និងក្រៅវិសាលភាពរបស់ប្រទេសកម្ពុជាក៏ជាកត្តាសំខាន់មួយផងដែរ សម្រាប់អត្ថិភាពយូរអង្វែងនៃបឹងទន្លេសាប។ នៅប្រទេសកម្ពុជា យើងបានស្នើរឡើងនូវសេចក្តីព្រាងច្បាប់ស្តីពីទឹក ដើម្បីគ្រប់គ្រង និង ប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធិភាព។ ច្បាប់ស្តីអំពីទឹកត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្រ្តី និងបញ្ជូនទៅរដ្ឋសភាដើម្បីពិចារណា និងអនុម័ត។

ប្រាកដណាស់ថា កិច្ចការទាំងអស់នេះជាការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ទាំងផ្នែកនយោបាយ និងស្ថាប័ន ចំពោះបុព្វហេតុការពារបឹងទន្លេសាប។ យើងនឹងបន្តខិតខំប្រឹងប្រែងធ្វើការឱ្យបានសម្រេច ដើម្បីជាប្រយោជន៍ដល់ប្រជាជនកម្ពុជា ទាំងអស់ ជាពិសេសអ្នកក្រីក្រ និងការថែរក្សាបរិស្ថាន។

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

សម្ពាធនៃកំណើនប្រជាជន វិសមភាពនៃសិទ្ធិទទួលផល និងភាពក្រីក្ររបស់ប្រជាជន ដែលពឹងផ្អែកលើធនធានទាំងនេះ ធ្វើអោយប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់យ៉ាងខ្លាំង។ ប្រការនេះ ធ្វើអោយបឹងទន្លេសាបប្រឈមនឹងគ្រោះគំរាមនៃការធ្វើអាជីវកម្មហួសកម្រិត ហើយប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបបានជួបប្រទះនឹងភាពងាយរងការបំផ្លិចបំផ្លាញ។ ជាការពិត ប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយទាន់ពេលវេលាទេនោះ កម្ពុជាអាចនឹងប្រឈមមុខចំពោះមហន្តរាយបរិស្ថានយ៉ាងធ្ងន់ធ្ងរ។

ជាមួយគ្នានេះដែរ មានកត្តាជាច្រើនដែលចូលរួមចំណែកក្នុងការគំរាមចំពោះបរិស្ថាន។ ក្នុងនោះកំណើនប្រជាជននៅតាមដងទន្លេនៅតែបន្តកើនឡើងឥតឈប់ឈរ។ កំណើននេះបណ្តាលមកពីការកើនឡើងចំនួនប្រជាជននៅតំបន់នោះស្រាប់ផង និងការហូរចូលប្រជាជនពីតំបន់ផ្សេងទៀតនៃបណ្តាខេត្តដទៃរបស់ប្រទេសផង។ ចលនាផ្លាស់ប្តូរប្រជាជននេះ គឺដើម្បីស្វែងរកមុខរបរចិញ្ចឹមជីវិត ដែលប្រការនេះបានក្លាយជាទម្ងន់មួយថែមទៀត ទៅលើការប្រើប្រាស់ធនធានបឹងទន្លេសាប។ ការគំរាមជាចម្បងដល់បឹងទន្លេសាប រួមមានការធ្វើអាជីវកម្មហួសហេតុលើធនធានជលផល និងធនធានសត្វព្រៃ ការប្រែក្លាយតំបន់ព្រៃលិចទឹកទៅជាផ្ទៃដីកសិកម្ម ការទន្ទ្រានយកដីនៅក្នុងតំបន់លិចទឹក ការកាប់ឈើធ្វើជាអុសពីព្រៃលិចទឹក និងការនេសាទខុសច្បាប់។ ការបាត់បង់តំបន់ព្រៃលិចទឹកជះឥទ្ធិពលធ្ងន់ធ្ងរដល់ផលនេសាទ ដោយសារការទន្ទ្រានយកដីក្នុងគោលបំណងធ្វើកសិកម្ម ក្នុងទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំ និងការកាប់ឈើធ្វើអុស ពីព្រោះធនធានថាមពលមានកម្រិត។

ទន្ទឹមនឹងនេះ ការធ្លាក់ចុះយ៉ាងលឿននៃធនធានធម្មជាតិនៅក្នុងអាងទន្លេសាប បណ្តាលឱ្យភាពក្រីក្រនៅតំបន់នោះមានកំរិតខ្ពស់ ព្រមទាំងដាក់សំពាធទៅលើធនធាននៃបឹងទន្លេសាប។ លើសពីនេះទៅទៀត ការកើនឡើងនូវការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតនៅតាមអាងទន្លេអាចបង្កើតនូវការបំពុលបរិស្ថានក្នុងបឹងទន្លេសាបយ៉ាងធ្ងន់ធ្ងរ។ ការគ្រប់គ្រងទឹកនៅប្រភពទឹកខាងលើអាចគំរាមដល់ជម្រកធម្មជាតិរបស់ពូជសត្វជាច្រើន ហើយបណ្តាលអោយមានជម្លោះក្នុងការប្រើប្រាស់ទឹកដើម្បីធ្វើវារីអគ្គិសនី ការប្រើប្រាស់ក្នុងស្រុក និងប្រព័ន្ធប្រឡាយទឹក។ លើសពីនេះទៅទៀត ការចាប់យកដីនៅក្នុងតំបន់ព្រៃលិចទឹក មិនថាតែនៅក្នុងគោលបំណងដើម្បីប្រើប្រាស់ទឹក កាប់ឈើ និងកាប់អុស ឬ ទន្ទ្រានព្រៃ ដើម្បីធ្វើកសិកម្ម ប្រការទាំងអស់នេះ នឹងបំផ្លាញដល់ស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី និងបង្ករឱ្យមានការហូរច្រោះដី ការខូចគុណភាពដី បាត់បង់ដីល្បាប់ ទឹកជំនន់ និងល្អក់ប្រភពទឹកនៅខាងក្រោម។

កត្តាដែលគ្រោះថ្នាក់បំផុតចំពោះបរិស្ថាន គឺការកាប់ទន្ទ្រានព្រៃឈើនៃព្រៃលិចទឹក ដើម្បីធ្វើស្រែក្នុងទ្រង់ទ្រាយធំ។ ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន សូមចាត់វិធានការជាបន្ទាន់ ដើម្បីប្រឆាំងនឹងទង្វើរដ៏មហន្តរាយនេះ និងរាយការណ៍ដោយ ផ្ទាល់មកខ្ញុំ ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាព។

វាជាការពិតណាស់ដែលថា រាល់ការរំខានដល់ជលវិទ្យានៃបឹង អាចមានផលអាក្រក់ដល់ជលផល។ ការសិក្សាជាច្រើនបានបង្ហាញថា កម្រិតខ្ពស់បំផុត និងជលផលនេសាទក្នុងបឹងទន្លេសាបមានទំនាក់ទំនងយ៉ាងជិតស្និទ។ ប្រការនេះមានន័យថា ផែនការ

អភិវឌ្ឍន៍បឹងទន្លេសាបត្រូវតែធ្វើឡើងដោយ ***អភិក្រមសមាហរណកម្មគ្រប់ដណ្តប់អាងទន្លេ*** (integrated basin wide approch) ទាំងមូល។ ក៏ប៉ុន្តែកិច្ចប្រឹងប្រែងដើម្បីស្រោចស្រង់បឹងទន្លេសាប និងអភិរក្សវាជាសម្បត្តិជាតិ ក៏ដូចជាសម្បត្តិពិភពលោក គួរតែត្រូវបានពង្រីកឱ្យលើសពីព្រំដែនកម្ពុជា។ នៅក្រៅកម្ពុជា កត្តាដែលសំខាន់ដែលគំរាមដល់ទន្លេសាប គឺការកើនឡើងនូវផលប៉ះពាល់ក្នុងការកសាងនូវរចនាសម្ព័ន្ធនៃជលវិទ្យាក្នុងអាងទន្លេមេគង្គ។

ដោយមើលឃើញនូវបញ្ហាបរិស្ថាន និងការកើនឡើងនូវជម្លោះលើការប្រើប្រាស់ធនធានធម្មជាតិ ខ្ញុំបានលើកឡើងនូវគំនិតផ្តួចផ្តើមស្តីពីកំណែទម្រង់វិស័យជលផល។ ជាក់ស្តែងក្នុងឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានសំរេចចិត្តផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងឡូតិ៍នេសាទពីវិស័យឯកជនទៅគ្រួសារ។ ជាលទ្ធផល ៥៦%(ប្រមាណ ៥០០.០០០ហិចតា)នៃតំបន់អតីតឡូតិ៍នេសាទ ដែលបានធ្វើអាជីវកម្មដោយវិស័យឯកជនត្រូវបានប្រគល់ទៅសហគមន៍មូលដ្ឋានជាអ្នកគ្រប់គ្រងទៅវិញ។ កំណែទម្រង់នេះ គឺមានបំណងផ្តល់នូវលទ្ធភាពឱ្យសហគមន៍ក្រីក្រមានសិទ្ធិក្នុងការប្រើប្រាស់ និងទទួលខុសត្រូវលើការគ្រប់គ្រងផលនេសាទ និងព្រៃលិចទឹកក្នុងប្រទេស រួមទាំងបឹងទន្លេសាបដើម្បីលើកកំពស់កាលានុវត្តភាពក្នុងការចិញ្ចឹមជីវិត និងសន្តិសុខស្បៀងអាហារ។ កំណែទម្រង់នេះ គឺជាការសំរេចដ៏ធំមួយក្នុងការផ្តល់អំណាចទៅអោយសហគមន៍នៅក្នុងអាងទន្លេសាប និង ផ្តល់ ឱ្យពួកគេនូវធនធានដើម្បីលើកកំពស់ចំណូល និងរបរចិញ្ចឹមជីវិត។ ជាលទ្ធផលនៃកំណែទំរង់នេះ សហគមន៍មូលដ្ឋានមានសិទ្ធិបន្ថែមទៀតក្នុងការទទួលនូវធនធានជលផល។ សហគមន៍អ្នកនេសាទចំនួន១៧៥ ត្រូវបានបង្កើតឡើង ដើម្បីជំរុញការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍។ វាជាការជឿជាក់យ៉ាងមុតមាំរបស់យើងដែលថា ការគ្រប់គ្រងសហគមន៍ជាមួយនឹងការគាំទ្រផ្នែកស្ថាប័ន និងហិរញ្ញវត្ថុយ៉ាងសមរម្យអាចជួយ ឱ្យសម្រេចនូវការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយសមធម៌។

ទោះជាយ៉ាងណាក៏ដោយ កំណែទម្រង់នេះមិនអាចដោះស្រាយនូវជម្លោះក្នុងតំបន់ទាំងស្រុងនោះទេ មានបញ្ហាជាច្រើនទៀតដែលចាំបាច់ត្រូវដោះស្រាយ ដើម្បីជួយសហគមន៍ឱ្យរួចផុតពីភាពក្រីក្រនិងគ្រប់គ្រងធនធានធម្មជាតិឱ្យសមស្របទៅនឹងការអភិវឌ្ឍន៍ប្រកបដោយចិរភាព។ បញ្ហាចំបង គឺការផ្តល់ឱ្យសហគមន៍នូវអំណាច ដើម្បីគ្រប់គ្រងដោយខ្លួនឯង។

ខ្ញុំមានមោទនភាពចំពោះសមិទ្ធផលរបស់ប្រជាជនកម្ពុជាដែលរស់នៅតាមដងទន្លេសាប ជាពិសេសចំពោះអ្នកដែលរួមចំនែកជាមួយនឹងរដ្ឋបាលមូលដ្ឋានក្នុងការគ្រប់គ្រងនេសាទ។ ថ្វីបើសកម្មភាពក្នុងការគ្រប់គ្រងបច្ចេកទេស និងចំណេះធ្វើរបស់ពួកគាត់នៅមានកម្រិត ពួកគាត់មានបំណងចង់ចូលរួម និងរៀនសូត្រ។ យើងបានបែងចែកនូវតំបន់ឡូតិ៍នេសាទធំៗ ជូនដល់សហគន៍នេសាទដើម្បីឱ្យសហគមន៍ក្រីក្រទទួលនូវផលប្រយោជន៍បន្ថែមទៀតក្រៅពីការនេសាទ។ ការការពារ និងគ្រប់គ្រងជលផល ព្រៃលិចទឹក និងសត្វព្រៃទាំងអស់បានក្លាយទៅជាកិច្ចការមួយរបស់សហគមន៍។ ខ្ញុំក៏សូមកោតសរសើរចំពោះមន្ត្រីជលផលរបស់យើង ដែលបានធ្វើការយ៉ាងសស្រាក់សស្រាំ ដើម្បីរៀបចំនូវសហគមន៍នេសាទ ទោះបីជាទស្សនៈ និងការអនុវត្តន៍អភិបាលកិច្ចមូលដ្ឋាន និងការគ្រប់គ្រងធនធានរបស់សហគមន៍ ជាគំនិតថ្មីស្រឡាងចំពោះពួកគាត់ភាគច្រើន។ ជារួម យើងបានសំរេចនូវការរីកចំរើនគួរឱ្យកត់សម្គាល់ និងបានទទួលការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការការពារបរិស្ថាន។

*-ឯកឧត្តម លោកជំទាវ លោក និង លោកស្រី*

ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀតថា ដោយសាមានបញ្ហាដ៏សាំញ៉ាំ ក្នុងការសម្របសម្រួលលើការទាមទាធនធានពីសំណាក់ស្រទាប់មនុស្សផ្សេងៗនៅក្នុងសង្គម ការអភិវឌ្ឍន៍បឹងទន្លេសាបគឺត្រូវរៀបចំផែនការ និងដាក់ឱ្យដំណើរការអនុវត្តន៍តាម ***អភិក្រមសមាហរណកម្មគ្រប់ដណ្តប់អាងទន្លេ*** ។ ក្នុងន័យនេះ ខ្ញុំសូមកោតសរសើរចំពោះ **គំនិតផ្តួចផ្តើមទន្លេសាប** ដែលបានរៀបចំឡើង

ដោយធនាគារអភិវឌ្ឍន៍អាស៊ី ហើយបានអនុម័តដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ ២០០៣ ដែលបានផ្តល់នូវក្របខ័ណ្ឌការងារ សម្រាប់ការគ្រប់គ្រងអាងទន្លេសាបទូលំទូលាយ ស្របតាម ***យុទ្ធសាស្ត្រចតុកោណ*** របស់រាជរដ្ឋាភិបាលដើម្បីកំណើនសេដ្ឋកិច្ច ការងារ សមធម៌ និង ប្រសិទ្ធិភាព។ ***ការផ្តួចផ្តើមបឹងទន្លេសាប*** បានបង្កើតនូវមូលដ្ឋានក្នុងការកំណត់អាទិភាព និងជំនួយផែនការក្នុងការអភិវឌ្ឍន៍ទន្លេសាប សម្រាប់ ៥-១០ ឆ្នាំខាងមុខទៀត។ មូលហេតុនេះហើយ ដែល **គំនិតផ្តួចផ្តើមទន្លេសាប** គឺជាទណ្ឌិករណ៍ដ៏ប្រសើរសម្រាប់បង្ហាញពីការអភិវឌ្ឍន៍ នូវយុទ្ធសាស្ត្របែបវិស័យក្រប់ដណ្តប់ (Sector wide approach)។

ក្នុងផ្នែកមួយនៃ***គំនិតផ្តួចផ្តើមបឹងទន្លេសាប*** យុទ្ធសាស្ត្រអភិវឌ្ឍអាងបឹងទន្លេសាប ត្រូវបានបង្កើតឡើងដោយមានការចូលរួមសហការពីបណ្តារដៃគូអភិវឌ្ឍន៍នានា ក្រោមរូបភាពជាកម្ចីជំនួយ និងគំរោងជំនួយបច្ចេកទេស។ ក្រៅពីធនាគារអភិវឌ្ឍន៍អាស៊ី ក៏មានអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគីពាក់ព័ន្ធនឹងការអភិវឌ្ឍន៍អាងបឹងទន្លេសាប ដូចជា ***អាអេហ្វដេ*** *(AFD)* ***អូសអេដ*** *(AusAid,* ***ប្រទេសប៊ែលស៊ិក ដានីដា*** (DANIDA) ***សហភាពអឺរ៉ុប*** (EU) ***អង្គការហ្វាវ*** (FAO) ***ជីអ៊ីអែហ្វ*** (GEF) ***ជីធីហ្សេត*** *(GTZ)* ***អាយអេហ្វ-អេឌី*** *(IFAD)* ប្រទេស***ហូឡង់*** ***ធនាគារពិភពលោក*** និង ***យូអិនឌីភី*** UNDP រួមទាំងបណ្តាអង្គការមិនមែនរដ្ឋាភិបាលជាច្រើនទៀត ។ ក្នុងនាមប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដល់បណ្តាដៃគូអភិវឌ្ឍន៍ខាងលើ ដែលបានឧបត្ថម្ភគាំទ្រ ដល់កម្ពុជាក្នុងការថែរក្សាប្រព័ន្ធជីវចំរុះបឹងទន្លេសាប។

ព្រមជាមួយនេះ គួរកត់សម្គាល់ថា ***គំនិតផ្តួចផ្តើមបឹងតន្លេសាប*** ត្រូវបានបង្កើតឡើង ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ដែលអាស្រ័យតាមដងទន្លេសាប តាមរយៈយុទ្ធសាស្ត្រគាំពារជនក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យបានប្រកបដោយចិរភាព។ ជាក់ស្តែង គ្រាន់តែក្នុងកំឡុងពេល ៣ ឆ្នាំ ប៉ុណ្ណោះ ***គំនិតផ្តួចផ្តើមបឹងទន្លេសាប*** បានអភិវឌ្ឍន៍យ៉ាងទូលំទូលាយសរុបទាំងកម្មវិធីប្រាក់កម្ចី ប្រាក់ជំនួយ និងគម្រោងជំនួយបច្ចេកទេសមានទឹកប្រាក់ប្រមាណជា ១៣០ លានដុល្លារ ដែលបានផ្តល់ឱ្យដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូហិរញ្ញប្បទានផ្សេងៗទៀត។ ទន្ទឹមនឹងនោះ គម្រោងទឹកប្រាក់ ៥៥ លានដុល្លាផ្សេងទៀតពីធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងត្រូវប្រើប្រាស់ដើម្បីការអភិវឌ្ឍន៍ និងការអនុវត្តន៍អភិក្រមគ្របដណ្តប់សំរាប់ការអភិវឌ្ឍន៍ និងគ្រប់គ្រងអាងទន្លេសាប ដើម្បីជួយអោយប្រជាជនចាកផុតពីភាពក្រីក្រ និងបង្កើតជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ និងអនុវត្តន៍អភិក្រមគ្របដណ្តប់បឹងទន្លេសាប។

*-ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី*

ការទទួលផលពីការផ្តួចផ្តើម សម្រាប់បឹងទន្លេសាបគួរឱ្យមានមោទនភាព ប៉ុន្តែសមរភូមិនៅមិនទាន់ទទួលជោគជ័យនៅឡើយទេ។ មានការងារជាច្រើនដែលត្រូវសម្រេចឱ្យបាន ដើម្បីធានាដល់ការអភិវឌ្ឍន៍ អាងបឹងទន្លេសាបប្រកបដោយចិរភាព។ ក្នុងស្មារតីនេះ យើងត្រូវបន្តអនុវត្តដូចតទៅ:

ទី១: ការបង្កើននូវការចែករំលែកគម្រោងនៅតាមថ្នាក់សហគមន៍ តាមរយៈការចូលរួមកិច្ចសហការជាមួយសហគមន៍ក្នុងការផ្តល់ មូលធនឥណទាន បច្ចេកវិជ្ជា ទីផ្សារ និងការលើកកំពស់ការសម្របសម្រួលរវាងភ្នាក់ងាររដ្ឋ និងសហគមន៍មូលដ្ឋាន

ទី២: ការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការសម្របសម្រួលកម្មវិធីនៅថ្នាក់ជាតិ ក្នុងចំណោមភាគីពាក់ព័ន្ធ រួមទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

ទី៣: ការជំរុញឱ្យកាន់តែខ្លាំងក្លាលើបទបញ្ញាតិស្តីពីការប្រើប្រាស់ និងទាញយកផលពីការអភិវឌ្ឍន៍ ដោយផ្តោតការយកចិត្តទុកដាក់លើការផ្តល់ភាពម្ចាស់ការនៅថ្នាក់សហគមន៍

ទី៤៖ ជំរុញការរៀបចំផែនការសកម្មភាពសម្រាប់គ្រប់គ្រងអាងទន្លេ និងការអភិវឌ្ឍន៍តាមវិស័យ រួមទាំងការកំណត់នូវគោលបំណង និងគោលដៅរយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងការផ្តល់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សពីគ្រប់ភាគីពាក់ព័ន្ធ

ទី៥៖ ធ្វើសមាហរណកម្ម ***ការផ្តួចផ្តើមបឹងទន្លេសាប*** ជាមួយគម្រោងវិមជ្ឈការ និងសហវិមជ្ឈការ ដោយកំណត់កម្មវិធី និងការអនុវត្តន៍ច្បាស់លាស់។

ដោយសារនេះជាការអន្តរាគមន៍ទៅលើប្រព័ន្ធអេកូឡូស៊ីដ៏ធំ និងគ្របដណ្តប់លើគ្រប់វិស័យ ***គំនិតផ្តួចផ្តើមបឹងទន្លេសាប*** តម្រូវឱ្យមានការរៀបចំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវ និងមានគណនេយ្យភាព ដែលជាប្រការអាចកៀរគរការគាំទ្រពីក្រសួងទាំងអស់ និងដៃគូអភិវឌ្ឍនានា។ នៅក្នុងន័យនេះ ខ្ញុំសូមស្នើរឱ្យវេទិកានេះ ពិភាក្សាលើលទ្ធភាពបង្កើត ***"អាជ្ញាធរទន្លេសាប"*** ឬ ***ឧត្តមក្រុមប្រឹក្សាទន្លេសាប*** នៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលដោយផ្ទាល់។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍អន្តរជាតិ ជាពិសេសធនាគារអភិវឌ្ឍន៍អាស៊ី ចំពោះជំនួយដល់អាងបឹងទន្លេសាប។ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាប្តេជ្ញាចូលរួមយ៉ាងសកម្មក្នុងកិច្ចសហការនេះរវាងសប្តាហ៍ខែឆ្នាំខាងមុខ។ យើងទន្ទឹងរង់ចាំសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូ អភិវឌ្ឍន៍ដទៃទៀត ដើម្បីប្រែក្លាយប្រាក់កម្ចី និងជំនួយឱ្យកាន់តែមានផលិតភាពនិងប្រសិទ្ធិភាពខ្ពស់ ដើម្បីពន្លឿនកំណើន និងការសម្រេចបានការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៅជនបទ។

ចុងបញ្ចប់ ខ្ញុំសូមជូនពរអោយវេទិការជាតិនេះទទួលបានជោគជ័យ និងសូមជូនពរសុខភាពល្អ និងជ័យជំនះក្នុងការអនុវត្តន៍គម្រោង និងកម្មវិធីនៃ ***ការផ្តួចផ្តើមបឹងទន្លេសាប***។

**ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់**